**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

ថ្ងៃអង្គារ ៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញរថយន្តមួយចំនួន

អនុលោមតាមអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានកិត្តិយស សូមជម្រាបជូនវិនិយោគិន ធុរជន និងភាគីពាក់ព័ន្ធទាំងអស់ ជ្រាបថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបញ្ចុះអត្រាអាករពិសេស លើមុខទំនិញរថយន្តមួយចំនួន ដែលនឹងចូលជាធរមានចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ នេះតទៅ។

អាស្រ័យហេតុនេះ ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ នេះតទៅ ការនាំចូលរថយន្តគ្រួសារ, រថយន្តដឹកទំនិញមួយចំនួន និងរថយន្តដឹកអ្នកដំណើរប្រភេទប្រើអគ្គិសនីសុទ្ធ ដូចមានចែងក្នុងអនុក្រឹត្យខាងលើ នឹងត្រូវជាប់កាតព្វកិច្ចពន្ធអាករកែសម្រួលថ្មី **ដោយគិតតាមកាលបរិច្ឆេទនៃការចុះបញ្ជីកាប្រតិវេទន៍គយ។** សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមទូរស័ព្ទលេខ 012 263 537, 070 507 705 និង 010 324 656។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន ធុរជន និងភាគីពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព។

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៤៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh

## តារាងសង្ខេប ស្ដីពី ការកែសម្រួលអត្រាអាករពិសេសលើរថយន្តមួយចំនួន

<table>
<tr><td colspan="7">I. រថយន្តគ្រួសារ</td></tr>
<tr><td rowspan="3">ប្រភេទថាមពល<br>ទំហំស៊ីឡាំង</td><td colspan="2">សាំងសុទ្ធ</td><td colspan="2">ម៉ាស៊ូតសុទ្ធ</td><td colspan="2">Hybrid</td></tr>
<tr><td colspan="2">អត្រាអាករពិសេស (%)</td><td colspan="2">អត្រាអាករពិសេស (%)</td><td colspan="2">អត្រាអាករពិសេស (%)</td></tr>
<tr><td>អត្រាចាស់</td><td>អត្រាថ្មី</td><td>អត្រាចាស់</td><td>អត្រាថ្មី</td><td>អត្រាចាស់</td><td>អត្រាថ្មី</td></tr>
<tr><td>មិនលើសពី 1000 cc</td><td>30</td><td>20</td><td rowspan="2">60</td><td rowspan="3">50</td><td>30</td><td>20</td></tr>
<tr><td>លើសពី 1000 cc ដល់ 2500 cc</td><td rowspan="3">60</td><td rowspan="3">50</td><td rowspan="3">60</td><td rowspan="3">50</td></tr>
<tr><td rowspan="2">លើសពី 2500 cc ដល់ 3000 cc</td><td>60*</td></tr>
<tr><td>70**</td><td rowspan="2">55</td></tr>
<tr><td>លើសពី 3000 cc</td><td>70</td><td>55</td><td>70</td><td>65</td><td>50</td></tr>
</table>

សម្គាល់៖

-រថយន្តលីម៉ូហ្ស៊ីនវែងគ្រប់ប្រភេទ ក្រៅពីប្រភេទប្រើថាមពលអគ្គិសនីសុទ្ធ ត្រូវបានបញ្ចុះពីអត្រាអាករពិសេសពី ៧០% មក ៥៥%

-* រថយន្តដែលមានទំហំស៊ីឡាំងលើសពី2500cc ដល់ 3000cc ប្រើថាមពលប្រេងម៉ាស៊ូត (លើកលែងតែរថយន្តផ្ទះគ្រប់ប្រភេទ និងរថយន្ត ភ្ជិដំឡើងរួចប្រភេទ 2WD ក្រៅពីសេដាន)

-** រថយន្តដែលមានទំហំស៊ីឡាំងលើសពី2500cc ដល់ 3000cc ប្រើថាមពលប្រេងម៉ាស៊ូត ជាប្រភេទរថយន្តផ្ទះ និងរថយន្តភ្ជិដំឡើងរួចប្រភេទ 2WD (ក្រៅពីសេដាន) ។

<table>
<tr><td rowspan="2">II. រថយន្តប្រើអគ្គិសនីសុទ្ធ</td><td colspan="2">អត្រាអាករពិសេស (%)</td></tr>
<tr><td>អត្រាចាស់</td><td>អត្រាថ្មី</td></tr>
<tr><td>រថយន្តគ្រួសារនិងរថយន្តដឹកអ្នកដំណើរ</td><td>30</td><td>10</td></tr>
<tr><td rowspan="2">III. រថយន្តដឹកទំនិញ</td><td colspan="2">អត្រាអាករពិសេស (%)</td></tr>
<tr><td>អត្រាចាស់</td><td>អត្រាថ្មី</td></tr>
<tr><td>រថសណ្ដោងសម្រាប់សីមីរ៉ឺម៉ក</td><td>40</td><td>25</td></tr>
<tr><td>រថយន្តដឹកទំនិញដែលមានទម្ងន់សរុប (ទម្ងន់រថយន្ត+ ទម្ងន់ផ្ទុក)<br>Gross Vehicle Weight > 5 តោន</td><td>40</td><td>30</td></tr>
<tr><td rowspan="2">IV. រថយន្តបែន រថយន្តស្ទូច និងរថយន្តឯកទេសផ្សេងទៀត</td><td colspan="2">អត្រាអាករពិសេស (%)</td></tr>
<tr><td>អត្រាចាស់</td><td>អត្រាថ្មី</td></tr>
<tr><td>រថយន្តបែន រថយន្តស្ទូច រថយន្តខ្ទង់ រថយន្តលាយបេតុង<br>រថយន្តផលិតកម្ម គ្រឿងរំសេវផ្ទុះចល័ត<br>និងប្រភេទប្រហាក់ប្រហែលផ្សេងទៀត</td><td>40</td><td>30</td></tr>
</table>

*(យោងអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ ស្ដីពី ការសម្រួលអត្រាអាករពិសេសលើមុខទំនិញរថយន្តមួយចំនួន ដែលនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១)*